# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ៦២១ គ.ជ.ប.ស.ស.រ

## សេចក្តីសម្រេច
## ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ស្របតាមមាត្រា ១៣៨ស្ទួន នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ និងបទបញ្ជា និងនីតិវិធីសម្រាប់ការអនុវត្តមាត្រា ១៣៨ស្ទួន នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៤៦៥/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- យោងប្រកាសលេខ ៥៤០៥ ប្រ ក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការលុបឈ្មោះគណបក្ស សង្គ្រោះជាតិ ចេញពីបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ
- យោងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៦១៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបែងចែកអាសនៈដែលនៅទំនេរស្របតាមមាត្រា ១៣៨ស្ទួន នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## <u>សម្រេច</u>

**ប្រការ១ :** ប្រកាសទទួលស្គាល់ជាផ្លូវការបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្ររបស់ **គណបក្ស ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច** តាមមណ្ឌលរាជធានី ខេត្ត ក្នុងនីតិកាលទី៥ នៃរដ្ឋសភា អនុលោមតាមមាត្រា ១៣៨ស្ទួន នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចមានក្នុងតារាងរាយនាមខាងក្រោម ៖

| ឈ្មោះមណ្ឌល | ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ផ្សេងៗ |
|---|---|---|---|---|---|
| ០៤ មណ្ឌល ខេត្ត កណ្ដាល | | | | | |
| | ១ | ឯកឧត្តម ហួន រាជចំរើន | ប្រុស | ០៥.០៥.១៩៦០ | |

**ប្រការ ២** : សេចក្ដីសម្រេចនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៣** : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចនេះជាសាធារណៈឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

សុិក ប៊ុនហុក

**ទូលថ្វាយ**

-ព្រះមហាក្សត្រ

**ចម្លងជូន**

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-រាជរដ្ឋាភិបាល

-គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

"ដើម្បីជូនជ្រាប"

-ដូចប្រការ៣ ដើម្បីអនុវត្ត

-បណ្ណសារដ្ឋានជាតិ

-ឯកសារ-កាលប្បវត្តិ